# ពិធីការសម្រាប់ហាងស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុកៈ ឧបសម្ព័ន្ធ Y
## មានប្រសិទ្ធិភាពចាប់ពីម៉ោង 12: 01រំលងអាធ្រាត្រ នៅថ្ងៃ ព្រហស្បតិ៍ ទី6 ខែ ឧសភា ឆ្នាំ2021

**បច្ចុប្បន្នភាពថ្មីៗ៖** (ការផ្លាស់ប្តូរត្រូវបានរំលេចដោយពណ៌លឿង)

**:2021/5/5**ទីតាំងខាងក្នុងអគារអាចបង្កើនការកំណត់ចំនួនមនុស្សអតិបរមា %50នៃទីតាំងទាំងមូល ឬចំនួនមនុស្ស 200 (6) នាក់ ហើយគឺកាន់តែតិចជាងនេះ។ នៅខាងក្នុងអគារ អតិថិជនដែលមកពីប្រាំមួយគ្រួសារអាចអង្គុយរួមគ្នាជាក្រុមចំនួនប្រាំមួយ ប្រសិនបើពួកគេបាចាក់វ៉ាក់សាំងពេញលេញ។ នៅខាងក្រៅ អតិថិជនដែលមកពីពីប្រាំបីគ្រួសារ អាចអង្គុយជាមួយគ្នាជាក្រុមដែលមានប្រាំបី ប្រសិនបើពួកគេចាក់វ៉ាក់សាំងពេញលេញ។ (8) ទូរទស្សន៍អាចបើកទាំងនៅក្នុង និងខាងក្រៅនៃទីតាំងបរិភោគអាហារបាន។

អត្រាករណី ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់ដោយសារជំងឺ COVID-19 មានការថយចុះខ្លះ ហើយហាក់ដូចជាមានស្ថេរភាព ប៉ុន្តែជំងឺ COVID-19 ក្នុងសហគមន៍ នៅមានកម្រិតមធ្យមនៅឡើយ។ ជំងឺ COVID-19 បន្តមានហានិភ័យ (risk) ខ្ពស់ចំពោះសហគមន៍ និងតម្រូវឲ្យមនុស្ស និងអាជីវកម្មទាំងអស់មានការប្រុងប្រយ័ត្ន និងកែប្រែប្រតិបត្តិការ និងសកម្មភាពដើម្បីកាត់បន្ថយហានិភ័យ (risk) នៃការរីករាលដាល។

ដោយសារខោនធី Los Angeles ចូលក្នុង "លំដាប់ថ្នាក់ពណ៌លឿង" "Yellow Tier"នៃផែនការដើម្បីសេដ្ឋកិច្ចមានសុវត្ថិភាពជាងមុន (Blueprint for a Safer Economy) របស់រដ្ឋ ពិធីការនេះត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីដកការរឹតត្បិតជាក់លាក់សម្រាប់សកម្មភាពក្នុងមូលដ្ឋានមួយចំនួន។ អាជីវកម្មគួរបន្តប្រតិបត្តិការប្រកបដោយការប្រុងប្រយ័ត្ន និងគោរពតាមលក្ខខ័ណ្ឌតម្រូវនៅក្នុងពិធីការនេះ ដើម្បីកាត់បន្ថយការរីករាលដាលនៃជំងឺ COVID-19 ដែលអាចកើតឡើងនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

ពិធីការនេះ និងល័ក្ខខ័ណ្ឌតម្រូវរបស់វាខាងក្រោមនេះ គឺជាក់លាក់សម្រាប់ការបើកឡើងវិញនៃកន្លែងធ្វើស្រា កន្លែងបិតស្រា និងរោងចម្រាញ់ស្រាដែលមានអាជ្ញាប័ណ្ណគ្រឿងស្រវឹងរបស់រដ្ឋលេខ #1, #2, #4, #23 និង #74 មិនមានលិខិតអនុញ្ញាតសុខភាពសាធារណៈសម្រាប់ភោជនីយដ្ឋាន និងដែលមិនផ្តល់សេវាម្ហូបអាហារ (ម្ហូបអាហារបន្ទាប់ពីចេញពីធ្វើការ) នៅនឹងកន្លែង។ អាជីវកម្មបែបនេះឥឡូវនេះអាចបើកប្រតិបត្តិការខាងក្នុងអគារក្នុងកម្រិត 50% នៃសមត្ថភាពផ្ទុកមនុស្សអតិបរមា ឬមនុស្ស 200 នាក់ មួយណាក៏ដោយដែលតិចជាង។

- កន្លែងបិតស្រា កន្លែងធ្វើស្រា និងរោងចម្រាញ់ស្រាដែលផ្តល់សេវាម្ហូបអាហារនៅនឹងកន្លែង ត្រូវតែគោរពតាមពិធីការសម្រាប់ភោជនីយដ្ឋាន៖ **ឧបសម្ព័ន្ធ I**។
- កន្លែងបិតស្រា កន្លែងធ្វើស្រា និងរោងចម្រាញ់ស្រាដែលត្រូវបានអនុញ្ញាតឲ្យលក់ស្រាបៀរ ស្រា ឬស្ពីរីត (spirit) ដែលត្រូវបានទទួលទាននៅក្រៅទីកន្លែងក៏ត្រូវបានតម្រូវឲ្យអនុវត្តតាមពិធីការសម្រាប់អាជីវកម្មលក់រាយ៖ **ឧបសម្ព័ន្ធ B** ផងដែរ។
- កន្លែងបិតស្រា កន្លែងធ្វើស្រា និងរោងចម្រាញ់ស្រាដែលជាអ្នកផលិតស្រាបៀរ ស្រា ឬស្ពីរីតក៏ត្រូវបានតម្រូវឲ្យអនុវត្តតាមពិធីការសម្រាប់អាជីវកម្មឃ្លាំងស្តុក ផលិត និងដឹកជញ្ជូន៖ **ឧបសម្ព័ន្ធ C** ផងដែរ។
- កន្លែងបិតស្រា កន្លែងធ្វើស្រា និងរោងចម្រាញ់ស្រាត្រូវតែបញ្ឈប់ប្រតិបត្តិហ្គេម ដែលរួមមានដូចជា កន្លែងបោះប៊ូលីង ក្តារគប់ព្រួញ និងតុប៊ីយ៉ា។ ហ្គេមឬសកម្មភាពទាំងនេះត្រូវបានអនុញ្ញាតឲ្យបើកដំណើរការដោយមានការកែប្រែ ឬប្រតិបត្តិការពេញលេញ។
- ហាងស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុកអាចមានការកម្សាន្តផ្ទាល់នៅខាងក្រៅអគារដោយស្របតាមពិធីសារភោជនីយដ្ឋាន។

កន្លែងធ្វើស្រា និងកន្លែងបិតស្រាដែលផលិតស្រា ឬស្រាបៀរដោយមានកន្លែងសម្រាប់ភ្លក្សស្រា ឬស្រាបៀរ ដែលត្រូវបានលើកលែងពីនិយមន័យពាក្យទីកន្លែងម្ហូបអាហារដោយច្បាប់សុខភាព និងសុវត្ថិភាពរដ្ឋ California ផ្នែក 113789(c)(5) និងមិនតម្រូវឲ្យមានលិខិតអនុញ្ញាតសុខភាពដើម្បីធ្វើប្រតិបត្តិការ អាចបើកដំណើរការសម្រាប់ការភ្លក្សទាំងនៅខាងក្នុងនិងខាងក្រៅអគារបាន។ រោងចម្រាញ់ស្រាអាចបើកដំណើរការសម្រាប់ការភ្លក្សទាំងនៅខាងក្នុងនិងខាងក្រៅអគារផងដែរ។

ហាងស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុកទាំងអស់ដែលដំណើរការត្រូវស្របតាមពិធីសារនេះអាចជួលកន្លែង និងរៀបចំជាម្ចាស់នៃព្រឹត្តិការណ៍ឯកជនស្របតាមពិធីសារខោនធីសម្រាប់ ព្រឹត្តិការណ៍ឯកជន៖ ឧបសម្ព័ន្ធ BBហាងស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុកដែលរៀបចំព្រឹត្តិការណ៍ឯកជនត្រូវតែបិទសម្រាប់អាជីវកម្មធម្មតាក្នុងកំឡុងពេលដែលមានការរៀបចំព្រឹត្តិការណ៍ឯកជននោះ។ លើកលែងថាហាងស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុកដែលមានកន្លែងរៀបចំព្រឹត្តិការណ៍ឯកជនដោយនៅទីតាំងដាច់ដោយឡែកដែលមានច្រកចូលដាច់ដោយឡែក និងកន្លែងដាច់ដោយឡែកអាចរៀបចំព្រឹត្តិការណ៍ឯកជនបាន ខណៈពេលដែលរក្សាប្រតិបត្តិការជាប្រចាំនៃអាជីវកម្មស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុក។ ក្នុងករណីបែបនេះ ព្រឹត្តិការណ៍ឯកជនដែលរៀបចំក្នុងពេលតំណាលគ្នាជាមួយអាជីវកម្មបើកប្រតិបត្តិការជាទៀងទាត់ គ្រប់ភ្ញៀវដែលមកចូលរួមសម្រាប់ព្រឹត្តិការណ៍ឯកជនមិនអាចលាយឡំជាមួយអតិថិជនចូលមកស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុកឡើយ។

ព្រឹត្តិការណ៍ឯកជនអាចត្រូវបានធ្វើឡើងនៅក្នុងអគារបាន លុះត្រាតែភ្ញៀវទាំងអស់បានចាក់វ៉ាក់សាំងពេញលេញបង្ការនៃជំងឺ COVID-19 ឬក៏ធ្វើតេស្តរកឃើញអវិជ្ជមាននៃជំងឺ COVID-19មុនពេលចូលរួមព្រឹត្តិការណ៍នេះ ដោយអនុលោមតាម[ពិធីសារសម្រាប់ព្រឹត្តិការណ៍ឯកជន]។
ភ្ញៀវព្រឹត្តិការណ៍ឯកជនទាំងអស់ត្រូវបង្ហាញភស្តុតាងដល់ប្រតិបត្តិកររបស់ហាងស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុកនៃការចាក់វ៉ាក់សាំងពេញលេញ ឬលទ្ធផលតេស្តឃើញលទ្ធផលអវិជ្ជមាននៃជំងឺ COVID-19ការហើមឬទឹកមាត់) មុនពេលចូលព្រឹត្តិការណ៍ឯកជន។

**សូមកត់សម្គាល់៖ ពិធីការនេះគឺមិនមែនសម្រាប់បារ (វារាប់បញ្ចូលទីកន្លែងដែលមានលិខិតអនុញ្ញាតសុខភាពសម្រាប់ភោជនីយដ្ឋានដែលមានហានិភ័យ (risk) ទាប)។ សូមមើល [ពិធីការបើកឡើងវិញសម្រាប់បារ៖ ឧបសម្ព័ន្ធ Y-1] សម្រាប់ល័ក្ខខ័ណ្ឌតម្រូវជាក់លាក់។**

ជំងឺ COVID-19 ភាគច្រើនឆ្លងនៅពេលដែលមនុស្សស្ថិតនៅជិតអ្នកដែលមានជំងឺ COVID-19 ឬមានការប៉ះពាល់ដោយផ្ទាល់ជាមួយបុគ្គលរូបនោះ។ នៅពេលដែលមនុស្សដែលមានជំងឺ COVID-19 ក្អក កណ្តាស់ ច្រៀង និយាយ ឬដកដង្ហើម ពួកគេបង្កើតតំណក់ទឹកតូចៗពីផ្លូវដង្ហើម។ ហើយដោយយោងតាមមជ្ឈមណ្ឌលត្រួតពិនិត្យ និងបង្ការជំងឺឆ្លង ហានិភ័យ (risk) នៃការឆ្លងជំងឺ COVID-19 កើនឡើងនៅតាមទីកន្លែងទាំងឡាយណាដែលមនុស្សម្នាដោះម៉ាស់របស់ខ្លួន ខណៈពេលបរិភោគ និងផឹក ហើយមានការប្រាស្រ័យទាក់ទងខ្ពស់ជាងមុនជាមួយមនុស្សដែលមិនរស់នៅក្នុងគ្រួសារតែមួយ។

- **ហានិភ័យ (Risk) ទាបបំផុត៖** សេវាកម្មម្ហូបអាហារ/ភេសជ្ជៈត្រូវបានដាក់កម្រិតត្រឹមការបើកចូល ការដឹកជញ្ជូន ការយកទៅបរិភោគខាងក្រៅ និងការមកយកនៅចិញ្ចើមថ្នល់។
- **ហានិភ័យ (Risk) ច្រើនជាងមុន៖** ការបើកចូល ការដឹកជញ្ជូន ការយកទៅបរិភោគខាងក្រៅ និងការមកយកនៅចិញ្ចើមថ្នល់ត្រូវបានសង្កត់ធ្ងន់។ សេវាកម្មបរិភោគអាហារ/ភេសជ្ជៈនៅទីកន្លែង ត្រូវបានដាក់កម្រិតត្រឹមការអង្គុយនៅខាងក្រៅអគារ។ ចំនួនកន្លែងអង្គុយ ត្រូវបានកាត់បន្ថយដើម្បីអនុញ្ញាតឲ្យរៀបតុឃ្លាតពីគ្នាជាងមុនថែមទៀត។
- **ហានិភ័យ (Risk) ខ្ពស់ជាងមុន៖** ការបរិភោគអាហារ/ការផឹកនៅនឹងកន្លែងដោយកាត់បន្ថយចំនួនកន្លែងអង្គុយខាងក្នុងអគារ ដើម្បីអនុញ្ញាតឲ្យរៀបតុឃ្លាតពីគ្នាជាងមុនថែមទៀត។ និង/ឬការបរិភោគអាហារ/ការផឹកនៅនឹងកន្លែងដោយមានការអង្គុយនៅខាងក្រៅអគារ ប៉ុន្តែតុមិនត្រូវបានរៀបឲ្យឃ្លាតពីគ្នាជាងមុនថែមទៀត។
- **ហានិភ័យ (Risk) ខ្ពស់បំផុត៖** ការបរិភោគអាហារ/ការផឹកនៅនឹងកន្លែងដោយមានការអង្គុយនៅខាងក្នុងអគារ។ ចំនួនកន្លែងអង្គុយមិនត្រូវបានកាត់បន្ថយ ហើយតុមិនត្រូវបានរៀបឃ្លាតពីគ្នាជាងមុនថែមទៀត។

នៅក្នុងពិធីការតទៅនេះ ពាក្យ "គ្រួសារ" មាននិយមន័យថាជា "មនុស្សដែលរស់នៅជាមួយគ្នាក្រោមដំបូលតែមួយ" និងមិនរាប់បញ្ចូលស្ថានភាពរស់នៅជាក្រុមស្ថាប័នដូចជាអន្តេវាសិកដ្ឋាន សមាគមបុរស សមាគមស្ត្រី វត្តអារាម អារាសដូនជី ឬទីកន្លែងថែទាំដែលមានការស្នាក់នៅ ហើយវាក៏មិនរាប់បញ្ចូលការរៀបចំឲ្យរស់នៅបែបពាណិជ្ជកម្ម ដូចជាផ្ទះជួល សណ្ឋាគារ ឬផ្ទះសំណាក់ដែរ[1] ពាក្យ "បុគ្គលិក" និង "និយោជិក" មានអត្ថន័យរាប់បញ្ចូលនិយោជិក អ្នកស្ម័គ្រចិត្ត បុគ្គលិកហាត់ការ និងសិក្ខាកាម បញ្ញវន្ត និងបុគ្គលផ្សេងៗទៀតទាំងអស់ដែលបម្រើការងារនៅទីកន្លែង។ ពាក្យ "ភ្ញៀវ" ឬ "អតិថិជន" គួរត្រូវបានយល់ថារាប់បញ្ចូលសាធារណជន និងជនដទៃទៀតដែលមិនមែនជាបុគ្គលិក ឬនិយោជិកដែលចំណាយពេលនៅអាជីវកម្ម ឬទីកន្លែង។ ពាក្យ "អាជីវកម្ម" "ទីកន្លែង" និង "មន្ទីរ" ទាំងពីរនេះសំដៅលើអគារ ទីធ្លា និងអគារឬទីធ្លាជាប់គ្នាដែលបានអនុញ្ញាតឲ្យធ្វើសកម្មភាព។ "LACDPH" គឺនាយកដ្ឋានសុខភាពសាធារណៈខោនធី Los Angeles។

បន្ថែមលើល័ក្ខខ័ណ្ឌទៅលើកន្លែងបិតស្រា កន្លែងធ្វើស្រា និងរោងចម្រាញ់ស្រាដែលបានដាក់ចុះដោយមន្ត្រីសុខាភិបាលសាធារណៈរបស់រដ្ឋ កន្លែងបិតស្រា កន្លែងធ្វើស្រា និងរោងចម្រាញ់ស្រាក៏ត្រូវតែគោរពតាមពិធីការស្តីពីសុវត្ថិភាព និងការគ្រប់គ្រងការឆ្លងជំងឺទាំងនេះផងដែរ។

សូមកត់សម្គាល់៖ ឯកសារនេះអាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលមានព័ត៌មាន និងធនធានបន្ថែម ដូច្នេះសូមប្រាកដថាពិនិត្យមើលគេហទំព័រ LA County http://www.ph.lacounty.gov/media/Coronavirus/ ជាប្រចាំសម្រាប់បច្ចុប្បន្នភាពផ្សេងៗទៅលើឯកសារនេះ និងការណែនាំដែលទាក់ទង។

បញ្ជីត្រួតពិនិត្យនេះគ្របដណ្តប់៖

(1) គោលការណ៍កន្លែងធ្វើការ និងការអនុវត្តដើម្បីការពារសុខភាពបុគ្គលិក
(2) វិធានការណ៍ដើម្បីធានាបាននូវការរក្សាគម្លាតរាងកាយ
(3) វិធានការណ៍ដើម្បីធានាបាននូវការគ្រប់គ្រងការឆ្លងជំងឺ
(4) ការទំនាក់ទំនងជាមួយបុគ្គលិក និងសាធារណជន
(5) វិធានការណ៍ដើម្បីធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព។

ចំណុចសំខាន់ៗទាំងប្រាំនេះត្រូវតែបានដោះស្រាយ នៅពេលដែលទីកន្លែងរបស់អ្នកបង្កើតពិធីការបើកឡើងវិញណាមួយ។

**ទីកន្លែងទាំងអស់ដែលត្រូវបានគ្របដណ្តប់ដោយពិធីការនេះ ត្រូវតែដាក់ចុះនូវវិធានការណ៍ដែលអាចអនុវត្តបាន**

[1] ច្បាប់ខោនធី Los Angeles ចំណងជើង 22. §22.14.060 - និយមន័យពាក្យគ្រួសារ (F. Family) ។ (បទបញ្ញត្តិ 2019-0004 § 1, 2019.) https://library.municode.com/ca/los_angeles_county/codes/code_of_ordinances?nodeId=TIT22PLZO_DIV2DE_CH22.14DE_22.14.060F

**ទាំងអស់ ដែលមានរាយនៅខាងក្រោម និងត្រូវត្រៀមខ្លួនដើម្បីពន្យល់ពីមូលហេតុនៃវិធានការណ៍ណាមួយ ដែលមិនត្រូវបានអនុវត្ត គឺមិនអាចអនុវត្តបានសម្រាប់អាជីវកម្ម។**

**ឈ្មោះអាជីវកម្ម៖** ____________________

**អាសយដ្ឋានទីកន្លែង៖** ____________________

**ចំនួនមនុស្សអតិបរមាពីមុន៖** ____________________

**ដែនកំណត់ចំនួនមនុស្ស៖** ____________________

**កាលបរិច្ឆេទចុះផ្សាយ៖** ____________________

## A. គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក (គូសធីកទាំងអស់ដែលអនុវត្តសម្រាប់ទីកន្លែង)

- ❑ មនុស្សគ្រប់គ្នាដែលអាចបំពេញកិច្ចការរបស់ខ្លួនពីផ្ទះ ត្រូវបានណែនាំឲ្យធ្វើដូច្នោះ។
- ❑ បុគ្គលិកងាយរងគ្រោះ (អ្នកដែលមានអាយុលើស 65 ឆ្នាំ អ្នកដែលមានផ្ទៃពោះ និងអ្នកដែលមានបញ្ហាសុខភាពប្រចាំកាយ) ត្រូវបានកំណត់ការងារដែលអាចធ្វើការពីផ្ទះគ្រប់ពេលដែលអាចធ្វើបាន និងគួរតែពិភាក្សាអំពីក្តីកង្វល់នានាជាមួយអ្នកផ្តល់សេវាសុខភាព ឬសេវាកម្មសុខភាពការងាររបស់ខ្លួន ដើម្បីធ្វើការសម្រេចចិត្តបានសមស្របអំពីការត្រឡប់ ទៅកន្លែងធ្វើការវិញ។
- ❑ បុគ្គលិកទាំងអស់ត្រូវបានប្រាប់ថាកុំមកធ្វើការបើសិនជាឈឺ ឬបើសិនជាពួកគេបានប៉ះពាល់ជាមួយបុគ្គលដែលមានជំងឺ COVID-19។
- ❑ ការត្រួតពិនិត្យការចូល ត្រូវបានធ្វើឡើងមុនពេលបុគ្គលិក អ្នកលក់ និងបុគ្គលិកដឹកជញ្ជូន អាចចូលមកក្នុងកន្លែងធ្វើការ ដោយយោងទៅតាម[ការណែនាំអំពីការត្រួតពិនិត្យការចូល]របស់ LACDPH។ ការពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យ ពាក់ព័ន្ធ នឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងគ្រុនក្តៅឬគ្រុនរងា និងថាតើបុគ្គលនោះកំពុង ស្ថិតក្រោមសេចក្តី បង្គាប់ឲ្យនៅដាច់ដោយឡែក និងឲ្យនៅដាច់ពីគេនាពេលបច្ចុប្បន្នឬអត់។ ការពិនិត្យទាំងនេះអាចត្រូវបានធ្វើឡើងពីចម្ងាយ ឬដោយផ្ទាល់បន្ទាប់ពីបុគ្គលិកមកដល់។ ការពិនិត្យសីតុណ្ហភាពក៏គួរតែធ្វើឡើងនៅកន្លែងធ្វើការផងដែរ បើសិនជាអាចធ្វើបាន។
  - o ការពិនិត្យឃើញអវិជ្ជមាន (គ្មានបញ្ហា)។ បើសិនជាបុគ្គលមិនមានរោគសញ្ញា និងមិនបានប៉ះពាល់ជាមួយករណីដែលគេដឹងថាជាករណីជំងឺ COVID-19 ក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ពួកគេអាចចូលសម្រាប់ថ្ងៃនោះបាន។
  - o ការពិនិត្យឃើញវិជ្ជមាន (មានបញ្ហា)៖
    - ▪ បើសិនជាបុគ្គលមិនបានចាក់វ៉ាក់សាំងពេញលេញប្រឆាំងនឹង[2]ជំងឺ COVID-19 និងមានការប៉ះពាល់ជាមួយករណីដែលគេដឹងថាមានជំងឺ COVID-19 ក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ឬបច្ចុប្បន្នកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ពីគេ ពួកគេមិនអាចចូល ឬធ្វើការនៅទីវាលបានទេ និងត្រូវតែបញ្ជូនទៅផ្ទះភ្លាមៗ ដើម្បីនៅដាច់ពីគេនៅផ្ទះ។ ផ្តល់ឲ្យពួកគេនូវការណែនាំអំពីការដាក់ឲ្យនៅដាច់ពីគេ ដែលមាននៅ [ph.lacounty.gov/covidquarantine]។
    - ▪ បើសិនជាបុគ្គលបង្ហាញចេញរោគសញ្ញាណាមួយនៃរោគសញ្ញាដែលបានកត់សម្គាល់ខាងលើ ឬកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែកនាពេលបច្ចុប្បន្ន ពួកគេមិនអាចចូល ឬធ្វើការនៅទីវាលបានទេ និងត្រូវតែបញ្ជូនទៅផ្ទះភ្លាមៗដើម្បីនៅដាច់ដោយឡែកនៅផ្ទះ។ ផ្តល់ឲ្យពួកគេនូវការណែនាំអំពីការដាក់ឲ្យនៅដាច់ដោយឡែក ដែលមាននៅ [ph.lacounty.gov/covidisolation]។
- ❑ បុគ្គលិកបានទទួលព័ត៌មានអំពីអត្ថប្រយោជន៍នៃការឈប់សម្រាកដែលឧបត្ថម្ភដោយនិយោជក ឬរដ្ឋាភិបាលដែលបុគ្គលិកអាចនឹងមានសិទ្ធិទទួល ដែលនឹងធ្វើឲ្យវាកាន់តែមានភាពងាយស្រួលផ្នែកហិរញ្ញវត្ថុក្នុងការស្ថិតនៅផ្ទះ។ មើលព័ត៌មានបន្ថែមស្តីពី [កម្មវិធីរដ្ឋាភិបាលដែលគាំទ្រការឈប់សម្រាកឈឺ និងសំណងបុគ្គលិកសម្រាប់ជំងឺ COVID-19] រួមទាំងសិទ្ធិសម្រាកឈប់សម្រាកឈឺរបស់បុគ្គលិកក្រោមច្បាប់ស្តីពី [ច្បាប់ឈប់សម្រាកដោយជំងឺCOVID-19បន្ថែម]។
- ❑ បន្ទាប់ពីទទួលព័ត៌មានថាមានបុគ្គលិកម្នាក់ ឬច្រើននាក់ធ្វើតេស្តវិជ្ជមាន ឬមានរោគសញ្ញាដែលដូចគ្នាជាមួយជំងឺ COVID-19 (ករណី) និយោជកមានគម្រោង ឬពិធីការដើម្បីឲ្យករណីទាំងនោះដាក់ខ្លួនឲ្យនៅដាច់ដោយឡែកនៅផ្ទះ និងតម្រូវឲ្យដាក់ខ្លួនឲ្យនៅដាច់ពីគេភ្លាមៗសម្រាប់បុគ្គលិកដែលមានការប៉ះពាល់ជាមួយករណីនៅកន្លែងធ្វើការ។ គម្រោងរបស់និយោជកគួរតែពិចារណាពីពិធីការសម្រាប់បុគ្គលិកដែលបាននៅដាច់ពីគេទាំងអស់ ដើម្បីអាចទទួលបាន ឬធ្វើតេស្តរកជំងឺ COVID-19 ដើម្បីកំណត់ថាតើមានការប៉ះពាល់នៅកន្លែងធ្វើការបន្ថែមទៀតឬអត់ ដែលអាចតម្រូវឲ្យមានវិធានការណ៍គ្រប់គ្រងជំងឺ COVID-19 បន្ថែម។ មើលការណែនាំសុខភាពសាធារណៈស្តីពី [ការឆ្លើយតបនឹងជំងឺ COVID-19 នៅកន្លែងធ្វើការ]។
- ❑ នៅក្នុងករណីដែលម្ចាស់អាជីវកម្ម អ្នកគ្រប់គ្រង ឬប្រតិបត្តិករដឹងថាមានករណីជំងឺ COVID-19 ចំនួនបី (3) ឬច្រើនជាងនេះ នៅកន្លែងធ្វើការក្នុងរយៈពេល 14 ថ្ងៃ នោះនិយោជកត្រូវតែរាយការណ៍ពីចង្កោមនេះទៅនាយកដ្ឋានសុខភាពសាធារណៈ

---

[2] មនុស្សដែលបានចាក់វ៉ាក់សាំងពេញលេញបង្ការជំងឺ COVID-19 រយៈពេលពីរ (2) សប្តាហ៍ឬច្រើនជាងនេះបន្ទាប់ពីពួកគេបានទទួលដូសទីពីរសម្រាប់វ៉ាក់សាំងដែលមាន 2 ដូស (ឧ. Pfizer-BioNTech ឬ Moderna) ឬពីរ (2) សប្តាហ៍ឬច្រើនជាងនេះបន្ទាប់ពីពួកគេបានទទួលវ៉ាក់សាំងដែលមានមួយដូស (ឧ. Johnson and Johnson [J&J]/Janssen)។

តាមរយៈលេខ (888) 397-3993 ឬ (213) 240-7821 ឬតាមអនឡាញនៅ www.redcap.link/covidreport ។ បើសិនជាចង្កោមត្រូវបានរកឃើញនៅកន្លែងធ្វើការ នាយកដ្ឋានសុខភាពសាធារណៈ នឹងចាប់ផ្តើមការឆ្លើយតបចំពោះការឆ្លងជាក្រុម ដែលរួមមានដូចជាការផ្តល់ការណែនាំ និងអនុសាសន៍អំពីការគ្រប់គ្រងការឆ្លងជំងឺ ការគាំទ្របច្ចេកទេស និងវិធានការណ៍គ្រប់គ្រងដែលជាក់លាក់សម្រាប់ទីកន្លែង។ អ្នកគ្រប់គ្រងករណីសុខភាពសាធារណៈ នឹងត្រូវបានចាត់តាំងដើម្បីធ្វើការស៊ើបអង្កេតការឆ្លងជាក្រុមដើម្បីដឹកនាំការឆ្លើយតបនៅទីកន្លែង។

- ☐ បុគ្គលិកដែលមានការប៉ះពាល់ជាមួយអ្នកដទៃបានទទួលម៉ាស់សមស្របដែលគ្របច្រមុះ និងមាត់ដោយឥតគិតថ្លៃ។ សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រម៉ាស់ជំងឺ COVID-19 របស់ LAC DPH នៅ http://publichealth.lacounty.gov/acd/ncorona2019/masks។ បុគ្គលិកត្រូវពាក់ម៉ាស់គ្រប់ពេលវេលា ក្នុងអំឡុងថ្ងៃធ្វើការ នៅពេលប៉ះពាល់ ឬទំនងជាប៉ះពាល់ជាមួយអ្នកដទៃ។ បុគ្គលិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនថាពួកគេមិនគួរពាក់ម៉ាស់ គួរពាក់សន្ទះបាំងមុខដែលមានក្រណាត់គ្របនៅគែមខាងក្រោម ដើម្បីអនុលោមតាមបទប្បញ្ញត្តិរបស់រដ្ឋ ដរាបណាលក្ខខ័ណ្ឌសុខភាពរបស់ពួកគេអនុញ្ញាត។ យកល្អគួរប្រើក្រណាត់គ្របដែលមានទម្រង់រឹងតឹងនៅខាងក្រោមចង្កា។ ម៉ាស់ដែលមានវ៉ាល់តែមួយផ្លូវគឺមិនគួរប្រើឡើយ។
- ☐ បុគ្គលិកត្រូវបានណែនាំអំពីការប្រើប្រាស់ និងការថែទាំម៉ាស់បានសមស្រប ដោយរាប់បញ្ចូលទាំងការពាក់វាពីលើច្រមុះ និងមាត់ និងភាពចាំបាច់ក្នុងការបោកគក់ ឬផ្លាស់ប្តូរម៉ាស់របស់ពួកគេជារៀងរាល់ថ្ងៃ។
- ☐ សន្ទះបាំងមុខត្រូវបានផ្តល់ជូនដល់ និងពាក់ដោយបុគ្គលិកទាំងអស់ដែលមិនទាន់បានចាក់វ៉ាក់សាំងពេញលេញ ដែលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជិតស្និទ្ធជាមួយអតិថិជន (នេះរាប់បញ្ចូលតែមិនដាក់កម្រិតត្រឹមអ្នកទទួលភ្ញៀវ និងបុគ្គលិកបម្រើភ្ញៀវដែលប្រាស្រ័យទាក់ទងជាមួយអតិថិជនក៏ដូចជាបុគ្គលិកផ្សេងៗទៀត ដូចជាអ្នកសម្អាត ឬ ផ្សេងៗទៀតដែលអាចចូលក្នុងទីកន្លែងទទួលភ្ញៀវខាងមុខ)។ សន្ទះបាំងមុខ ត្រូវបានពាក់បន្ថែមទៅលើម៉ាស់។ ម៉ាស់ការពារអ្នកដទៃពីតំណក់ទឹកតូចៗរបស់អ្នកពាក់។ សន្ទះបាំងមុខជួយការពារអ្នកពាក់ពីតំណក់ទឹកតូចៗពីអ្នកដទៃ។ដែលមិនទាន់ចាក់វ៉ាក់សាំងពេញលេញ និងរបាំងមុខគឺស្រេចចិត្តសម្រាប់បុគ្គលិកពេលដែលពួកគេមានបង្ហាញភស្តុតាងដែលអាចទទួលយកបានអំពីការចាក់វ៉ាក់សាំងពេញលេញដល់និយោជករបស់ពួកគេ
ការពាក់ម៉ាសនៅតែទាមទារឱ្យអនុវត្ត។សម្រាប់បុគ្គលិកដែលបានទទួលថ្នាំបង្ការពេញលេញដែលបានបង្ហាញភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញរបស់ពួកគេប្រឆាំងនឹងជំងឺ COVID-19 ហើយជ្រើសរើសមិនពាក់របាំងមុខ និយោជកគួរតែបង្កើត និងរក្សាកំណត់ត្រាជាលាយលក្ខណ៍អក្សរដែលឯកសារដែលបុគ្គលិកម្នាក់បានបង្ហាញភស្តុតាងដែលអាចទទួលយកបានជាភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញ។
និយោជកមិនចាំបាច់រក្សាទុកច្បាប់ចម្លងនៃភស្តុតាងការចាក់វ៉ាក់សាំងពេញលេញដែលបានបង្ហាញនោះទេ។
    - បុគ្គលដែលត្រូវបានគេចាត់ទុកថាជាការចាក់វ៉ាក់សាំងប្រឆាំងមេរោគ ≤COVID-19គ្រប់ចំនួនគឺគិតចាប់ពី ច្រើនជាង (រួម) 2សប្តាហ៍ បន្ទាប់ពីពេលពួកគេទទួលបានការចាក់ដូសទីពីរ នៃប្រភេទវ៉ាក់សាំងមាន ឬ Pfizer -BioNTech (Modernaឬច្រើនជាង ≥2សប្តាហ៍ បន្ទាប់ពីពេលពួកគេទទួលថ្នាំវ៉ាក់សាំងនៃ ប្រភេទដូសតែមួយដងរួចរាល់ហើយ (Johnson and Johnson [J&J]/Janssen រួមមាន)។
    - ខាងក្រោមនេះគឺអាចទទួលយកបានសម្រាប់បុគ្គលិកដោយគ្រាន់តែបង្ហាញទៅនិយោជិករបស់ពួកគេជាភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញបង្ការជំងឺ COVID-19៖ ប័ណ្ណចាក់វ៉ាក់សាំងដែលរួមបញ្ចូលទាំងឈ្មោះអ្នកដែលបានចាក់វ៉ាក់សាំង ប្រភេទវ៉ាក់សាំងដែលបានផ្តល់ជូន) និងកាលបរិច្ឆេទនៃដូសចុងក្រោយដែលនឹងត្រូវផ្តល់ជូន ឬរូបថតនៃប័ណ្ណចាក់វ៉ាក់សាំងជាឯកសារដាច់ដោយឡែក ( ឬរូបថតនៃកាតវ៉ាក់សាំងរបស់អ្នកដែលត្រូវបានរក្សាទុកនៅក្នុងទូរស័ព្ទ ឬឧបករណ៍អេឡិចត្រូនិក ដែលរួមមានឈ្មោះអ្នកដែលបានចាក់ថ្នាំបង្ការ) ឬឯកសារនៃការចាក់វ៉ាក់សាំងពីមណ្ឌលថែទាំសុខភាព និងបញ្ជាក់ថាពួកគេបានចាក់វ៉ាក់សាំងពេញលេញបង្ការជំងឺ (COVID-19។
- ☐ សន្ទះបាំងមុខ គឺត្រូវប្រើសម្អាត និងសម្លាប់មេរោគទៅតាមការណែនាំរបស់ក្រុមហ៊ុនផលិត។
- ☐ ដើម្បីធ្វើឲ្យប្រាកដថាម៉ាស់ត្រូវបានពាក់យ៉ាងខ្ជាប់ខ្ជួន និងត្រឹមត្រូវ បុគ្គលិកត្រូវបានហាមឃាត់មិនឲ្យបរិភោគ ឬផឹក លើកលែងតែក្នុងអំឡុងពេលការសម្រាករបស់ពួកគេ នៅពេលដែលពួកគេអាចដោះម៉ាស់របស់ខ្លួន និងរក្សាគម្លាតរាងកាយពីអ្នកដទៃបានដោយសុវត្ថិភាព។ នៅគ្រប់ពេលវេលាទាំងអស់នៅពេលបរិភោគ ឬផឹក បុគ្គលិកត្រូវតែរក្សាគម្លាតយ៉ាងតិច 6 ហ្វីតពីអ្នកដទៃ។ នៅពេលបរិភោគ ឬផឹក វាជាការប្រសើរដែលត្រូវធ្វើដូច្នោះនៅខាងក្រៅអគារ និងឆ្ងាយពីអ្នកដទៃ។
- ☐ ចំនួនបុគ្គលិកដែលបម្រើអតិថិជន ឬក្រុមនីមួយៗ គួរត្រូវបានកំណត់ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីប្រាក់ឈ្នួល និងម៉ោងធ្វើការ។
- ☐ ចំនួនមនុស្សត្រូវបានកាត់បន្ថយ ហើយគម្លាតរវាងបុគ្គលិក ត្រូវបានបង្កើនជាអតិបរមានៅក្នុងបន្ទប់ ឬកន្លែងនានា ដែលបុគ្គលិកប្រើសម្រាប់បរិភោគអាហារនិង/ឬសម្រាក។ ចំណុចនេះត្រូវបានសម្រេចដោយៈ
    - កំណត់ចំនួនមនុស្សអតិបរមាដែលអនុញ្ញាតឲ្យមានការរក្សាគម្លាតយ៉ាងតិចប្រាំមួយហ្វីតរវាងបុគ្គលនៅក្នុងបន្ទប់ ឬកន្លែងដែលប្រើសម្រាប់ការសម្រាក
    - ផ្លាស់ម៉ោងសម្រាក ឬម៉ោងបរិភោគអាហារ ដើម្បីកាត់បន្ថយចំនួនមនុស្សនៅក្នុងបន្ទប់ ឬទីកន្លែងដែលប្រើសម្រាប់ការបរិភោគអាហារ និងសម្រាក និង
    - ដាក់តុឃ្លាតពីគ្នាយ៉ាងតិចប្រាំបីហ្វីត ដោយយកកៅអី ឬបិទបង់ស្អិតលើកៅអីដើម្បីកាត់បន្ថយចំនួនមនុស្ស ដាក់គ្រឿងសម្គាល់លើកម្រាលឥដ្ឋដើម្បីធានាបាននូវការរក្សាគម្លាត និងរៀបចំកន្លែងអង្គុយតាមរបៀបមួយ ដែលកាត់បន្ថយការប៉ះពាល់ទល់មុខគ្នា។ ការប្រើប្រាស់របាំងខណ្ឌចែក ត្រូវបានលើកទឹកចិត្តដើម្បីទប់ស្កាត់ការរីករាលដាលបន្ថែមទៀត ប៉ុន្តែមិនគួរចាត់ទុកថាជាវិធីជំនួសឲ្យការកាត់បន្ថយចំនួនមនុស្ស និងការរក្សាគម្លាតរាងកាយឡើយ។

- ❑ បុគ្គលិកត្រូវបានណែនាំឲ្យប្រាកដថាការអនុវត្តអនាម័យដៃ ដែលរួមមានភាពញឹកញាប់នៃការលាងដៃ ការប្រើប្រាស់ទឹកអនាម័យលាងដៃ និងការប្រើប្រាស់ស្រោមដៃបានសមស្រប ត្រូវបានគោរពតាម។
- ❑ បុគ្គលិកត្រូវបានអនុញ្ញាតពេលវេលាដើម្បីលាងដៃរបស់ខ្លួនឲ្យបានញឹកញាប់។
- ❑ បុគ្គលិកត្រូវបានរំលឹកឲ្យខ្ទប់មាត់ពេលក្អក និងកណ្តាស់ដោយប្រើក្រដាសជូតមាត់។ ក្រដាសជូតមាត់ដែលបានប្រើរួច គួរបោះចោលក្នុងធុងសម្រាម និងលាងដៃភ្លាមៗជាមួយសាប៊ូនិងទឹកក្តៅអ៊ុនៗរយៈពេលយ៉ាងតិច 20 វិនាទី។
- ❑ បុគ្គលិក អ្នកលក់ និងបុគ្គលិកដឹកជញ្ជូនទាំងអស់បានទទួលការណែនាំទាក់ទងនឹងការរក្សាគម្លាតរាងកាយ និងការប្រើប្រាស់ម៉ាស់ ពេលនៅជិតអ្នកដទៃ។
- ❑ បន្ទប់សម្រាក បន្ទប់ទឹក និងទីកន្លែងទូទៅផ្សេងទៀត ត្រូវបានសម្លាប់មេរោគដោយតាមភាពញឹកញាប់ដូចខាងក្រោម ប៉ុន្តែមិនតិចជាងម្តងក្នុងមួយក្នុងមួយថ្ងៃក្នុងអំឡុងម៉ោងប្រតិបត្តិការ ទៅតាមកាលវិភាគដូចខាងក្រោម៖
  - ○ បន្ទប់សម្រាក ______________________
  - ○ បន្ទប់ទឹក ______________________
  - ○ ផ្សេងទៀត ______________________
- ❑ សារធាតុសម្លាប់មេរោគ និងការផ្គត់ផ្គង់ដែលពាក់ព័ន្ធគឺមានសម្រាប់បុគ្គលិកនៅទីតាំងដូចខាងក្រោម៖

  ______________________________________________
- ❑ ទឹកអនាម័យលាងដៃដែលមានប្រសិទ្ធភាពប្រឆាំងជំងឺ COVID-19 គឺមានសម្រាប់បុគ្គលិកទាំងអស់នៅទីតាំងដូចខាងក្រោម៖

  ______________________________________________
- ❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានចែកចាយទៅបុគ្គលិកទាំងអស់។
- ❑ ស្រេចចិត្ត—ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

  ______________________________________________

## B. វិធានការណ៍ដើម្បីធានាបាននូវការរក្សាគម្លាតរាងកាយ

**ទីកន្លែងខាងក្នុងអគារ៖**

- ❑ ចំនួនអតិថិជននៅកន្លែងអង្គុយខាងក្នុងអគារត្រូវកំណត់ត្រឹម 50% នៃសមត្ថភាពផ្ទុកខាងក្នុងអគារ ឬអ្នកចូលរួម 200 នាក់ជាអតិបរមា មួយណាក៏ដោយដែលតិចជាង។ នៅពេលដែលអាចធ្វើបាន ចំណតយានយន្តត្រូវបានរៀបចំឡើងវិញដើម្បីដាក់កម្រិតលើចំណុចកកស្ទះ និងធានាបាននូវការឃ្លាតឆ្ងាយបានសមស្រប។
  - ○ ចំនួនអតិថិជនអតិបរមានៅក្នុងទីកន្លែងបរិភោគអាហារខាងក្នុងអគារត្រូវបានដាក់កម្រិតត្រឹម៖

    ______________________
- ❑ ដើម្បីធានាបាននូវការរក្សាគម្លាតរាងកាយយ៉ាងតិច 6 ហ្វីតរវាងអតិថិជនដែលអង្គុយនៅតុខុសៗគ្នា តុត្រូវតែមានចន្លោះពីគ្នាយ៉ាងហោចណាស់ ៦ (6) ហ្វីតពីគ្នា ដោយវាស់កៅអីខាងក្រោយនៅតាមតុទល់នឹងកៅអីខាងក្រោយដែលមានតុជាប់ជិតគ្នានោះ ខណៈពេលអតិថិជនបានអង្គុយដែរ។ នេះក៏អនុញ្ញាតឲ្យមានកន្លែងដើរកាត់ចន្លោះតុ និងគិតគូរនៅពេលកៅអីត្រូវបានរុញចេញក្រៅ និងប្រើដោយអតិថិជន ដែលអង្គុយនៅនឹងតុផងដែរ។ កញ្ចក់ Plexiglass ឬរបាំងផ្សេងទៀតមិនជំនួសឲ្យគម្លាតរវាងតុ និងគម្លាត 6 ហ្វីតរវាងអ្នកបរិភោគអាហារដែលបានតម្រូវឡើយ។ មើលផ្នែក "ឧទាហរណ៍នៃការរៀបចំកន្លែងអង្គុយដែលបានអនុម័តនៅក្នុងចំនួនមនុស្សដែលអាចអនុញ្ញាតបាន" ខាងក្រោម។
- ❑ កន្លែងអង្គុយខាងក្នុងអគារនៅតុមួយនៅនឹងកន្លែង ត្រូវកំណត់មិនឲ្យលើសមនុស្សប្រាំមួយ (6) នាក់នៅក្នុងក្រុមតែមួយឡើយ។ មនុស្សទាំងអស់ដែលអង្គុយនៅនឹងតុខាងក្នុងអគារ ត្រូវតែជាសមាជិកក្នុងគ្រួសារតែមួយ ដូច្នេះ មិនចាំបាច់អង្គុយឃ្លាតពីគ្នាប្រាំមួយហ្វីតឡើយ។ មុនពេលអង្គុយ អ្នកទទួលភ្ញៀវត្រូវតែជម្រាបជូនព័ត៌មានដោយផ្ទាល់មាត់ដល់ក្រុមនោះថាមនុស្សគ្រប់គ្នាដែលកំពុងអង្គុយនៅតុតែមួយនៅខាងក្នុងអគារ ត្រូវតែមកពីគ្រួសារតែមួយ។
- ❑ ប្រសិនបើសមាជិកទាំងអស់នៃពិធីជប់លៀងបញ្ជាក់ និងបង្ហាញភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញប្រឆាំងនឹងជំងឺ COVID-19[3] ពួកគេអាចនឹងអង្គុយជាមួយគ្នារហូតដល់ទៅប្រាំមួយ (6) នាក់ក្នុងមួយតុ និងដែលមកពីប្រាំមួយ(6)គ្រួសារផ្សេងគ្នា។ អតិថិជនដែលបានបញ្ជាក់ការចាក់វ៉ាក់សាំងពេញលេញត្រូវតែបង្ហាញទៅប្រតិបត្តិករនូវការផ្ទៀងផ្ទាត់ចាំបាច់ ដែលជាអត្តសញ្ញាណប័ណ្ណ និងភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញ (ដែលរួមបញ្ចូលទាំងឈ្មោះអ្នកដែលបានចាក់វ៉ាក់សាំង ប្រភេទវ៉ាក់សាំងCOVID-19ដែលបានផ្តល់ជូន និងកាលបរិច្ឆេទនៃដូសចុងក្រោយដែលនឹងត្រូវផ្តល់ជូន) ឬរូបថតនៃប័ណ្ណចាក់វ៉ាក់សាំងជាឯកសារដាច់ដោយឡែក ឬរូបថតនៃកាតវ៉ាក់សាំងរបស់អ្នកដែលត្រូវបានរក្សាទុកនៅក្នុងទូរស័ព្ទ ឬឧបករណ៍អេឡិចត្រូនិក ឬឯកសារនៃការចាក់វ៉ាក់សាំងពីមណ្ឌលថែទាំសុខភាព មុនពេលពួកគេអាចអង្គុយរួមគ្នាបាន។

---

[3] បុគ្គលដែលត្រូវបានគេចាត់ទុកថាជាការចាក់វ៉ាក់សាំងប្រឆាំងមេរោគCOVID-19គ្រប់ចំនួនគឺគិតចាប់ពីពីរ (2) សប្តាហ៍ឬច្រើនជាងនេះបន្ទាប់ពីពេលពួកគេទទួលបានការចាក់ដូសទីពីរនៃប្រភេទវ៉ាក់សាំង (រួមមានPfizer-BioNTech ឬModerna) ឬ 2សប្តាហ៍ ឬច្រើនជាងនេះបន្ទាប់ពីពេលពួកគេទទួលថ្នាំវ៉ាក់សាំងនៃប្រភេទដូសតែមួយដងរួចរាល់ហើយ (រួមមាន Johnson and Johnson [J&J]/Janssen)។

### ទីកន្លែងខាងក្រៅអគារ៖

- ❑ ចំនួនអតិថិជននៅកន្លែងអង្គុយខាងក្រៅអគារ គឺតិចល្មមដើម្បីធានាបាននូវការរក្សាគម្លាតរាងកាយ។ តុត្រូវតែមានចន្លោះពីគ្នាយ៉ាងហោចណាស់ ៦ (6) ហ្វីតដាច់ពីគ្នា ដោយវាស់កៅអីខាងក្រោយនៅតាមតុទល់នឹងកៅអីខាងក្រោយដែលមានតុជាប់ជិតគ្នានោះ ខណៈពេលអតិថិជនបានអង្គុយដែរ។ ហើយក៏អនុញ្ញាតឱ្យមានផ្លូវកាត់បន្ទប់រវាងតុនីងតុគឺតលយដែលមានកៅអីដែលត្រូវរុញវា ចេញនិងមានអតិថិជនអង្គុយនៅតុនោះ។ ធ្វើបែបនេះដើម្បីទុកឲ្យមានចន្លោះដើរកាត់រវាងតុ និងដើម្បីគិតគូដល់កៅអីដែលអតិថិជនអង្គុយ និងរុញចេញខណៈពេលអង្គុយនៅនឹងតុ។ កញ្ចក់ Plexiglass ឬបាំងផ្សេងទៀតមិនជំនួសឲ្យគម្លាតរវាងតុ និង រវាងអតិថិជនដែលបានតម្រូវឡើយ។ មើលផ្នែក "ឧទាហរណ៍នៃការរៀបចំកន្លែងអង្គុយដែលបានអនុម័តនៅក្នុងចំនួនមនុស្សដែលអាចអនុញ្ញាតបាន" ខាងក្រោម។ ចំនួនអតិថិជនអតិបរមានៅក្នុងទីកន្លែងអង្គុយខាងក្រៅអគារត្រូវបានដាក់កម្រិតត្រឹម៖ ____________, ដូចបានកំណត់ដោយចំនួនសរុបនៃកៅអីដែលមានបន្ទាប់ពីតុត្រូវបានរៀបឲ្យឃ្លាតពីគ្នាយ៉ាដូចបានពិពណ៌នាខាងលើ និងមានកៅអីអង្គុយច្រើនបំផុតប្រាំមួយ (6) ក្នុងមួយតុ។
- ❑ កន្លែងអង្គុយខាងក្រៅអគារនៅតុមួយនៅនឹងកន្លែង ត្រូវកំណត់មិនឲ្យលើសមនុស្សប្រាំបី (8) នាក់នៅក្នុងក្រុមតែមួយឡើយ។ មនុស្សទាំងអស់ដែលអង្គុយនៅនឹងតុខាងក្រៅអគារ មិនអាចមកពីគ្រួសារខុសៗគ្នាលើសពីបីគ្រួសារបានឡើយ។ មុនពេលអង្គុយ 1) សមាជិកទាំងអស់នៅក្នុងក្រុម ត្រូវតែមានវត្តមាន និង 2) អ្នកទទួលភ្ញៀវត្រូវតែជម្រាបជូនព័ត៌មានដោយផ្ទាល់មាត់ដល់ក្រុមនោះថា មនុស្សគ្រប់គ្នាដែលនៅតុតែមួយមិនអាចមកពីគ្រួសារខុសៗគ្នាលើសពីបីគ្រួសារបានឡើយ។
- ❑ ប្រសិនបើសមាជិកទាំងអស់នៃពិធីជប់លៀងបញ្ជាក់ និងបង្ហាញភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញប្រឆាំងនឹងជំងឺ COVID-19[4] ពួកគេអាចអង្គុយជាមួយគ្នាបានរហូតដល់ប្រាំបីនាក់ (8) នាក់ក្នុងមួយតុ និងរហូតដល់ទៅប្រាំបីគ្រួសារ (8) ផ្សេងគ្នា។ អតិថិជនដែលបានបញ្ជាក់ការចាក់វ៉ាក់សាំងពេញលេញត្រូវតែបង្ហាញទៅប្រតិបត្តិករនូវការផ្ទៀងផ្ទាត់ចាំបាច់ដែលជាអត្តសញ្ញាណប័ណ្ណ និងភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញ (ដែលរួមបញ្ចូលទាំងឈ្មោះអ្នកដែលបានចាក់វ៉ាក់សាំង ប្រភេទវ៉ាក់សាំង COVID-19ដែលបានផ្តល់ជូន និងកាលបរិច្ឆេទនៃដូសចុងក្រោយដែលនឹងត្រូវផ្តល់ជូន) ឬរូបថតនៃប័ណ្ណចាក់វ៉ាក់សាំងជាឯកសារដាច់ដោយឡែក ឬរូបថតនៃកាតវ៉ាក់សាំងរបស់អ្នកដែលត្រូវបានរក្សាទុកនៅក្នុងទូរស័ព្ទ ឬឧបករណ៍អេឡិចត្រូនិក ឬឯកសារនៃការចាក់វ៉ាក់សាំងពីមណ្ឌលថែទាំសុខភាព មុនពេលពួកគេអាចអង្គុយរួមគ្នាបាន។
- ❑ ទីកន្លែងដែលប្រើប្រាស់រចនាសម្ព័ន្ធខាងក្រៅអគារទាំងឡាយ ត្រូវតែអនុលោមតាមលក្ខណៈវិនិច្ឆ័យរបស់រដ្ឋសម្រាប់ទីកន្លែងខាងក្រៅអគារ ដូចបានបញ្ជាក់នៅក្នុងការណែនាំចាំបាច់របស់នាយកដ្ឋានសុខាភិបាលរដ្ឋ California ស្តីពី ការប្រើប្រាស់រចនាសម្ព័ន្ធបណ្តោះអាសន្នសម្រាប់ប្រតិបត្តិការអាជីវកម្មខាងក្រៅអគារ។ រចនាសម្ព័ន្ធខាងក្រៅអគារដែលមិនឆ្លើយតបតាមលក្ខណៈវិនិច្ឆ័យរបស់រដ្ឋសម្រាប់ទីកន្លែងខាងក្រៅអគារ ត្រូវបានចាត់ថ្នាក់ថាជាទីកន្លែងខាងក្នុងអគារ និងត្រូវបានកំណត់ចំនួនត្រឹម50% ។

### ល័ក្ខខ័ណ្ឌតម្រូវទូទៅសម្រាប់ទីកន្លែងទាំងអស់៖

- ❑ អតិថិជនទាំងអស់ដែលមកដល់ទីកន្លែងសម្រាប់សេវានៅខាងក្នុងអគារត្រូវតែមានការកក់ទុកជាមុន។ ប្រព័ន្ធកក់ទុកជាមុនរបស់អាជីវកម្មគួរត្រូវបានប្រើដំណើងឲ្យទូរសព្ទចូលជាមុនដើម្បីបញ្ជាក់ពីចំនួនមនុស្សដែលអង្គុយ/បម្រើនៅពេលដែលអាចធ្វើបាន។ ព័ត៌មានទំនាក់ទំនងសម្រាប់ភាគីនីមួយៗត្រូវបានប្រមូលនៅពេលកក់ទុកមុន ឬនៅនឹងកន្លែងបើអាចអនុវត្តបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដើម្បីអនុញ្ញាតឲ្យមានការតាមដានការប៉ះពាល់បើសិនជាវាត្រូវបានតម្រូវ។
    - ○ បញ្ជរបារដែលត្រូវបានប្រើក្នុងគោលបំណងរៀបចំ ឬបម្រើជូនភេសជ្ជៈគ្រឿងស្រវឹង ត្រូវបានបិទសម្រាប់សេវាភេសជ្ជៈនៅបញ្ជរនោះ។
    - ○ អតិថិជនអាចបរិភោគ ឬផឹកខណៈដែលអង្គុយនៅនឹងតុក្នុងទីកន្លែងបរិភោគអាហារដែលបានកំណត់ប៉ុណ្ណោះ។ អតិថិជនទាំងអស់ត្រូវតែពាក់ម៉ាស់ពេលស្ថិតនៅលើទីតាំង លុះត្រាតែពួកគេកំពុងបរិភោគ ឬកំពុងផឹកខណៈដែលអង្គុយនៅតុបរិភោគអាហារ។
- ❑ ព្រឹត្តិការណ៍ឯកជន៖
    - ○ ហាងស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុកអាចរៀបចំព្រឹត្តិការណ៍ឯកជន (ឧទាហរណ៍ការទទួលភ្ញៀវ ការប្រជុំ ឬពិធីជប់លៀង) ទាំងនៅខាងក្នុងអគារ ឬខាងក្រៅនៃទីកន្លែង ដោយព្រឹត្តិការណ៍ឯកជនទាំងនេះត្រូវតែអនុលោមតាមសុខភាពសាធារណៈរបស់ខោនធីអំពី ពិធីសារសម្រាប់ព្រឹត្តិការណ៍ឯកជន៖ ឧបសម្ព័ន្ធ BB។
    - ○ ប្រសិនបើហាងស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុកមិនមានកន្លែងរៀបចំព្រឹត្តិការណ៍ឯកជនដោយនៅទីតាំងដាច់ដោយឡែក ដែលមានច្រកចូលពីគ្នាទេនោះ ព្រឹត្តិការណ៍ឯកជនអាចត្រូវបានធ្វើឡើងនៅពេលដែលហាងស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុកបិទសម្រាប់ប្រតិបត្តិការអាជីវកម្មធម្មតា។ ទោះបីជាយ៉ាងណាក៏ដោយ ហាងស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុកដែលមានកន្លែងរៀបចំព្រឹត្តិការណ៍ឯកជនដោយនៅទីតាំងដាច់ដោយឡែកដែលមានច្រកចូលដាច់ដោយឡែក និងកន្លែងដាច់ដោយឡែកអាចរៀបចំព្រឹត្តិការណ៍ឯកជនបានខណៈពេលដែលរក្សាប្រតិបត្តិការជាប្រចាំនៃអាជីវកម្មស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុក។ គ្រប់ភ្ញៀវដែលមកចូលរួមសម្រាប់ព្រឹត្តិការណ៍ឯកជនមិនអាចលាយឡំជាមួយអតិថិជនចូលមកហាងស្រាបៀរ ស្រាវីស្គី

[4] បុគ្គលដែលត្រូវបានគេចាត់ទុកថាជាការចាក់វ៉ាក់សាំងប្រឆាំងមេរោគCOVID-19គ្រប់ចំនួនគឺគិតចាប់ពីពីរ (2) សប្តាហ៍ឬច្រើនជាងនេះបន្ទាប់ពីពេលពួកគេទទួលបានការចាក់ដូសទីពីរនៃប្រភេទវ៉ាក់សាំង (រួមមានPfizer-BioNTech ឬModerna) ឬ 2សប្តាហ៍ ឬច្រើនជាងនេះបន្ទាប់ពីពេលពួកគេទទួលថ្នាំវ៉ាក់សាំងនៃប្រភេទដូសតែមួយដងរួចរាល់ហើយ (រួមមាន Johnson and Johnson [J&J]/Janssen)។

និងហាងស្រាក្រឡុកឡើយ។

- ចំនួនអតិបរមានៃទីតាំងអាគារទាំងមូលសម្រាប់រៀបចំព្រឹត្តិការណ៍ឯកជនណាមួយត្រូវធ្វើឡើងនៅខាងក្រៅអគារដោយមានមនុស្ស 200 នាក់ ហើយអាចនឹងកើនឡើងដល់ 400 នាក់ ប្រសិនបើភ្ញៀវទាំងអស់បានធ្វើតេស្តឃើញលទ្ធផលអវិជ្ជមាន ឬបានចាក់វ៉ាក់សាំងពេញលេញបង្ការជំងឺ COVID-19 ដូចមានចែងក្នុងពិធីសារសុខភាពសាធារណៈរបស់ខោនធី សម្រាប់ព្រឹត្តិការណ៍ឯកជន។ ព្រឹត្តិការណ៍ឯកជនដែលបានរៀបចំឡើងនៅខាងក្នុងអគារនៅតាមហាងស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុកបាន លុះត្រាតែភ្ញៀវទាំងអស់បានធ្វើតេស្តឃើញលទ្ធផលអវិជ្ជមាន ឬបានចាក់វ៉ាក់សាំងពេញលេញបង្ការជំងឺ COVID-19 ដូចមានចែងក្នុងពិធីសារសុខភាពសាធារណៈរបស់ខោនធី សម្រាប់ព្រឹត្តិការណ៍ឯកជន។ ឧបសម្ព័ន្ធ BB ព្រឹត្តិការណ៍ឯកជនអាចត្រូវបានធ្វើឡើងនៅក្នុងអគារបានគឺមានចំនួន 150 នាក់។
- ប្រសិនបើហាងស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុកត្រូវបានរៀបចំក្នុងពេលតំណាលគ្នាជាមួយព្រឹត្តិការណ៍ឯកជនដោយធ្វើឡើងនៅក្នុងទីតាំងនោះ ទីតាំងហាងស្រាបៀរ ស្រាវីស្គី និងហាងស្រាក្រឡុក និងទីតាំងព្រឹត្តិការណ៍ឯកជនត្រូវបានគណនាដាច់ដោយឡែកពីគ្នា។

- [ ] ការកម្សាន្តផ្ទាល់ខាងក្រៅអគារត្រូវបានអនុញ្ញាត។ត្រូវតែមានការកំណត់ព្រំដែនដែលអាចមើលឃើញដើម្បីរក្សាគម្លាតយ៉ាងតិច 12 ហ្វីតរវាងទីតាំងអង្គុយនៃក្រុមអតិថិជន និងឆាកសម្រាប់អ្នកសំដែង។ អ្នកសម្តែងគួរតែប្រើមីក្រូហ្វូនសម្រាប់ការសម្តែងដល់កម្រិតអតិបរិមាតាមដែលអាចធ្វើទៅបាន ដូច្នេះអ្នកសំដែងអាចកំណត់សំឡេង ដើម្បីកាត់បន្ថយកាកល្អិត ដំណក់តូចៗ និងដំណក់ទឹកដែលបញ្ចេញ និងសាយភាយទៅឆ្ងាយ។ ការកម្សាន្តបន្តផ្ទាល់នៅខាងក្នុងអគារមិនអនុញ្ញាតឡើយ។
- [ ] **សម្រាប់អ្នកសម្តែងតន្ត្រី៖**
  - អ្នកសម្តែងតន្ត្រីគួរតែជូតសម្អាតបំពង់ដែលអាចដក់ទឹកដោយប្រើក្រណាត់កន្សែងដែលអាចចោលបានឬក្រដាសនៅពេលណាដែលអាចធ្វើទៅបានហើយដាក់ចេញពីអ្នកដទៃនៅពេលផ្លុំ ឬបញ្ចេញសារធាតុទឹកចេញដើម្បីចៀសវាងការចម្លងរោគ។ តន្ត្រីករគួរបោះចោលកន្សែងដែលបានប្រើដោយខ្លួនឯង ហើយលាងដៃ និង/ ឬប្រើទឹកលាងដៃកម្ចាត់មេរោគបន្ទាប់ពីបោះចោល។ ប្រសិនបើតន្ត្រីករជូតសម្អាតបំពង់ដែលអាចដក់ទឹកដោយប្រើក្រណាត់កន្សែងដែលៗកន្សែងនោះត្រូវតែបោកសម្អាតនៅពេលបញ្ចប់ជាមួយការសម្តែង ឬហាត់សម ពេលតន្ត្រីករត្រូវដាក់វាចូលក្នុងប្រអប់បិទជិត និងយកកន្សែងចេញឆ្ងាយពីអ្នកដទៃសម្រាប់បោកសម្អាត ហើយតន្ត្រីករត្រូវតែលាងដៃនិង/ឬប្រើទឹកអនាម័យ។ ។
  - អនុវត្តការសម្អាតឧបករណ៍ រួមមានការជូត និងផ្លុំចោលពីផ្ទះនិងឆ្ងាយពីអ្នកដទៃមុននិងក្រោយពេលមានការសម្តែង។
  - កុំចែករំលែកឧបករណ៍ ប្រសិនបើអាចធ្វើទៅបាន។ ពិចារណាក្នុងការបញ្ឈប់រកជំនួយពីជំនួយការតន្ត្រីករ ដូចជាអ្នកថែរក្សាសៀវភៅណោទភ្លេង ឬបុគ្គល ផ្សេងទៀតដែលមិនអាចរក្សាគម្លាតយ៉ាងតិច 6ហ្វីតនោះ។
  - បង្កើនការរក្សាគម្លាតរវាងមនុស្សដែលច្រៀង ឬច្រៀងតាមចម្រៀងនិងអ្នកដទៃទៀត ឬរវាងអ្នកសម្តែងឧបករណ៍លង្ហិន/ខ្យល់ និងអ្នកផ្សេងទៀតឲ្យបានចន្លោះធំជាង 6 ហ្វីតនៅពេលនៅខាងក្រៅ និងមិនពាក់របាំងមុខ។ ពិចារណាប្រើរនាំងដើម្បីបន្ថែមចន្លោះនៅក្នុងករណីទាំងនេះ។
  - អ្នកលេងតន្ត្រីដោយប្រើឧបករណ៍ខ្យល់គួរតែមានការកែប្រែបន្ថែមដែលសមស្រប ដូចជាឧបករណ៍ដើម្បីបាំងដំណក់តូចៗ ឬបង្វែរឧបករណ៍ខ្យល់នោះទៅតាមបរិយាកាស។
- [ ] ការរាំកម្សាន្តរបស់អតិថិជននៅតែត្រូវហាមឃាត់។ ការចាក់តន្ត្រីដែលបានថតទុក ត្រូវបានអនុញ្ញាត ប៉ុន្តែកម្រិតសំឡេងត្រូវតែទាបល្មមដើម្បីឲ្យបុគ្គលិកអាចស្តាប់ឮអតិថិជនខណៈដែលរក្សាគម្លាតរបស់ពួកគេ។
- [ ] ទូរទស្សន៍ ឬអេក្រង់ផ្សេងទៀតអាចត្រូវបានប្រើសម្រាប់ការទស្សនារបស់អតិថិជននៅខាងក្នុងនិងខាងក្រៅអគារ។
- [ ] នៅពេលដែលអាចធ្វើបាន ផ្លូវច្រកចូលតែមួយដែលបានកំណត់ច្បាស់លាស់ និងច្រកចេញដាច់ដោយឡែកដើម្បីជួយអនុវត្តការរក្សាគម្លាតរាងកាយ។
- [ ] វិធានការណ៍ដើម្បីធានានូវការរក្សាគម្លាតរាងកាយ ត្រូវបានអនុវត្តតាមនៅទីកន្លែងដែលអតិថិជន ឬបុគ្គលិកតម្រង់ជួរ។ នេះរួមមានដូចជាកន្លែងគិតលុយ ជួរបញ្ជា បន្ទប់ទឹក រានហាលជណ្តើរយន្តប្រអប់ កន្លែងទទួលភ្ញៀវ និងកន្លែងរង់ចាំ កន្លែងចតរថយន្តនៅចំណតរថយន្ត និងទីកន្លែងផ្សេងៗទៀតដែលអតិថិជនប្រមូលផ្តុំ។
  - បិទស្លាកស្ទីគ ឬគ្រឿងសម្គាល់ផ្សេងទៀតនៅចន្លោះ 6 ហ្វីតនៅគ្រប់ទីកន្លែងដែលសាធារណជនអាចបង្កើតជាជួរ ឬឈរ។
  - បើសិនជាអាចធ្វើបាន បង្កើតផ្លូវក្នុងអគារ និងផ្លូវដើរកាត់មានទិសដៅសម្រាប់ចរាចរណ៍ថ្មើរជើង ដើម្បីលុបបំបាត់ការដែលបុគ្គលិក និងអតិថិជនដើរកាត់គ្នា។
  - បើសិនជាអាចធ្វើបាន បុគ្គលិកម្នាក់ដែលពាក់សន្ទះបាំងមុខ និងម៉ាស់ត្រូវបានដាក់ឲ្យប្រចាំការនៅជិតកន្លែងផ្នែកខាងលើ ប៉ុន្តែមានគម្លាតយ៉ាងតិច 6 ហ្វីតពីអតិថិជនដែលជិតបំផុត ដើម្បីត្រួតពិនិត្យថាការរក្សាគម្លាតរាងកាយត្រូវបានអនុវត្តតាម។
- [ ] នៅពេលអាចធ្វើបាន ដំណោះស្រាយបច្ចេកវិទ្យាត្រូវបានអនុវត្តដើម្បីកាត់បន្ថយការប្រាស្រ័យទាក់ទងរវាងមនុស្សនឹងមនុស្ស ការបញ្ជាទិញតាមឧបករណ៍ចល័ត ថេប្លិតម៉ឺនុយ អត្ថបទនៅពេលមកដល់សម្រាប់កន្លែងអង្គុយ ជម្រើសទូទាត់ប្រាក់ដោយមិនបាច់បះ។
- [ ] រៀបចំការប្រាស្រ័យទាក់ទងរវាងអតិថិជន អ្នកបើកបររថយន្តដឹកជញ្ជូន និងបុគ្គលិកដើម្បីអនុញ្ញាតឲ្យមានការរក្សាគម្លាតរាងកាយ។

ច្បាប់ចាស់ - មិនមានប្រសិទ្ធភាព

   - កម្រាលឥដ្ឋនៅខាងក្នុង និងខាងក្រៅអាជីវកម្មនៅក្នុងទីកន្លែងដែលអតិថិជន អ្នកលក់ បុគ្គលិកដឹកជញ្ជូន ឬអ្នកដទៃទៀតអាចរង់ចាំ ត្រូវបានគូសសម្គាល់ដើម្បីអនុញ្ញាតឲ្យមាន និងអនុវត្តការរក្សាគម្លាតរាងកាយ។
   - ការប្រើប្រាស់ដំណើរការដែលមិនមានការប៉ះសម្រាប់ការទៅយកទំនិញ និងការដឹកជញ្ជូន ក៏ដូចជាប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀតសម្រាប់ការប្រាស្រ័យទាក់ទងគ្នារបស់ភ្ញៀវត្រូវបានអនុវត្ត នៅពេលដែលអាចធ្វើបាន។
   - ការប្រាស្រ័យទាក់ទងគ្នារវាងបុគ្គលិក និងអតិថិជនត្រូវបានដាក់កម្រិតត្រឹមប្រាំនាទីជាអតិបរមា នៅពេលដែលអាចធ្វើបាន។
- ❑ ដាក់កម្រិតការប៉ះពាល់រវាងបុគ្គលិក និងអតិថិជន។
   - ដំឡើងរបាំងពិតដូចជាការបំបែក ឬកញ្ចក់ plexiglass នៅកន្លែងចុះឈ្មោះ កន្លែងអ្នកទទួលភ្ញៀវឈរ បញ្ជរកម្មង់ ។ល។ នៅទីកន្លែងដែលពិបាកក្នុងការរក្សាគម្លាតរាងកាយប្រាំមួយហ្វីត។
   - ដាក់កម្រិតចំនួនបុគ្គលិកដែលបម្រើក្រុមបុគ្គល។
- ❑ រារាំងបុគ្គលិក និងអតិថិជនកុំឲ្យប្រមូលផ្តុំនៅទីកន្លែងដែលមានចរាចរណ៍ច្រើន ដូចជាបន្ទប់ទឹក ផ្លូវដើរក្នុងអគារ តំបន់បារ កន្លែងកក់ទុកមុន និងឧបករណ៍អានកាតឥណទាន ។ល។
- ❑ ពិធីការនៃការរក្សាគម្លាតរាងកាយគួរត្រូវបានប្រើនៅគ្រប់ទីកន្លែងការិយាល័យ ផ្ទះបាយ កន្លែងចែកម្ហូបអាហារ ម៉ាស៊ីនបង្អក ដើរចូល ឬទីកន្លែងបុគ្គលិកដែលមានចរាចរណ៍ខ្ពស់ផ្សេងទៀត។
   - ការប៉ះពាល់បន្តិចបន្តួចត្រូវបានរំពឹង ទោះជាយ៉ាងណាគោលដៅគឺដើម្បីដាក់កម្រិតវាឲ្យតិចជាង 15 នាទី យកល្អគឺ 10 នាទី ហើយបុគ្គលិកពាក់ម៉ាស់របស់ខ្លួនជានិច្ច។

## ការពិចារណាបន្ថែមសម្រាប់ការភ្លក្ស

- ❑ ផ្តល់កែវស្អាតសម្រាប់ការភ្លក្សនីមួយៗ និងបើអាចធ្វើបាន ចូរកុំចាក់ស្រាចូលក្នុងកែវដែលអតិថិជនបានប្រើរួច (ហិតក្លិន បានភ្លក្ស ។ល។)
- ❑ ការប្រើប្រាស់ធុងសម្រាប់រួម ធុងខាកស្តោះ កន្ថោរ ។ល។ ត្រូវតែបញ្ឈប់។
   - ផ្តល់ពែងនីមួយៗដែលប្រើហើយអាចបោះចោលបានដល់ភ្ញៀវនីមួយៗ ដើម្បីចៀសវាងការឆ្លងមេរោគដោយសារការខ្ទាតរវាងភ្ញៀវ។
- ❑ កុំប៉ះកប្រដាប់ផ្ទុកស្រា ដូចជាពែង កែវ ។ល។ នៅពេលចាក់ស្រា ស្រាបៀរ ឬស្ពីរិត។
- ❑ ចាត់វិធានការណ៍ដើម្បីធានាថា ពេលវេលានៃការណាត់ជួបជាក្រុមដើម្បីភ្លក្ស មិនជាន់គ្នាដើម្បីកាត់បន្ថយការប្រាស្រ័យទាក់ទងរបស់មនុស្សមកពីក្រុម និងទីកន្លែងខុសៗគ្នា។
- ❑ បញ្ឈប់ការដើរកម្សាន្ត ដែលរួមបញ្ចូលបុគ្គលមកពីគ្រួសារខុសៗគ្នាចូលទៅក្នុងក្រុមដើរកម្សាន្តតែមួយ។ មគ្គុទេសក៍ទេសចរណ៍ត្រូវតែរក្សាគម្លាតរាងកាយយ៉ាងតិចប្រាំមួយហ្វីតពីអតិថិជន/ភ្ញៀវ។

## C. វិធានការណ៍ដើម្បីគ្រប់គ្រងការឆ្លងជំងឺ

## មុនពេលបើកដំណើរការ

- ❑ ប្រព័ន្ធ HVAC ត្រូវបានត្រួតពិនិត្យដោយអ្នកឯកទេស HVAC ក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីបើកឡើងវិញ និងស្ថិតក្នុងសភាពដំណើរការល្អ។ ការបញ្ចេញបញ្ចូលខ្យល់ត្រូវបានបង្កើនឡើងដល់កម្រិតអតិបរមាតាមដែលអាចធ្វើបាន។ ការបញ្ចេញបញ្ចូលខ្យល់ដែលមានប្រសិទ្ធភាព គឺជាវិធីសំខាន់បំផុតមួយដើម្បីគ្រប់គ្រងការចម្លងតំណក់ទឹកតូចៗនៅក្នុងខ្យល់។
   - ពិចារណាដំឡើងម៉ាស៊ីនសម្អាតខ្យល់មានប្រសិទ្ធភាពខ្ពស់ចល័ត អាប់គ្រេតតម្រងខ្យល់របស់អគារឲ្យមានប្រសិទ្ធភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន និងធ្វើការកែប្រែផ្សេងទៀតដើម្បីបង្កើនបរិមាណខ្យល់ខាងក្រៅ និងខ្យល់បញ្ចូលនៅក្នុងទីកន្លែងធ្វើការទាំងអស់។
   - មើល ការណែនាំបណ្តោះអាសន្នសម្រាប់ការបញ្ចេញបញ្ចូលខ្យល់ ការចម្រោះ និងគុណភាពខ្យល់ក្នុងបរិស្ថានខាងក្នុងអគារ របស់នាយកដ្ឋានសុខភាពសាធារណៈរដ្ឋ California សម្រាប់ព័ត៌មានលម្អិត។
   - សម្គាល់សម្គាល់៖ ការបញ្ចេញបញ្ចូលខ្យល់ និងការកែលម្អគុណភាពខ្យល់ខាងក្នុងអគារផ្សេងទៀត គឺជាការបន្ថែមទៅលើ និងមិនមែនជាការជំនួសឲ្យការការពារចាំបាច់ដូចជាការពាក់ម៉ាស់ (លើកលែងក្នុងបរិស្ថានដែលមានហានិភ័យខ្ពស់ជាក់លាក់ ដែលតម្រូវឲ្យមានការការពារផ្លូវដង្ហើមសមស្រប) ការរក្សាគម្លាតយ៉ាងតិចប្រាំមួយហ្វីតរវាងមនុស្ស ការលាងដៃឲ្យបានញឹកញាប់ និងការដាក់កម្រិតសកម្មភាពដែលនាំមនុស្សមកពីគ្រួសារខុសៗគ្នាឲ្យមកនៅជុំគ្នានោះឡើយ។
- ❑ សម្រាប់ទីកន្លែងដែលមិនបានធ្វើប្រតិបត្តិការ ចូរបង្ហូរទឹកក្តៅនិងទឹកត្រជាក់លាយគ្នារយៈពេលប្រាំនាទីមុននឹងបើកឡើងវិញ ដើម្បីប្តូរទឹកនៅក្នុងបំពង់ទឹកជាមួយនឹងការផ្គត់ផ្គង់ទឹកដែលសាប និងមានសុវត្ថិភាព។
- ❑ ទីកន្លែងត្រូវបានសម្អាត និងធ្វើអនាម័យ/សម្លាប់មេរោគយ៉ាងហ្មត់ចត់ (ដោយប្រើផលិតផលដែលបានអនុម័តឲ្យប្រើប្រឆាំងនឹងជំងឺ COVID-19) ជាពិសេសបើសិនជាវាត្រូវបានបិទទ្វារ។
   - ផ្តល់ជម្រើសសម្រាប់ក្រុមហ៊ុនសម្អាតរបស់ភាគីទីបីដើម្បីជួយជាមួយតម្រូវការសម្អាតកើនឡើង តាមការចាំបាច់។
- ❑ ទីធ្លាដូចជាកន្លែងអង្គុយខាងក្នុងអគារ និងខាងក្រៅអគារ កន្លែងអ្នកទទួលភ្ញៀវឈរ និងកន្លែងរៀបចំភេសជ្ជៈត្រូវបាន

បំពាក់ទៅដោយផលិតផលអនាម័យសមស្រប ដូចជាទឹកអនាម័យលាងដៃ និងក្រដាសជូតអនាម័យសម្រាប់បុគ្គលិកទាំងអស់ដែលកំពុងជួយអតិថិជនដោយផ្ទាល់។

- ធ្វើឲ្យប្រាកដថាទីកន្លែងអនាម័យនៅបន្តប្រតិបត្តិការ និងមានស្តុកគ្រប់ពេលវេលា ហើយផ្តល់សាប៊ូ ក្រដាសជូត និងទឹកអនាម័យលាងដៃបន្ថែមនៅពេលចាំបាច់។
- ណែនាំឲ្យដំឡើងឧបករណ៍បាញ់ដោយមិនបាច់ប៉ះសម្រាប់ទឹកអនាម័យលាងដៃ ឧបករណ៍បញ្ចេញសាប៊ូ ក្រដាសជូត និងធុងសម្រាម។

❑ កន្លែងទម្លាក់ ត្រូវបានកំណត់ដើម្បីទទួលការដឹកជញ្ជូនឆ្ងាយពីកន្លែងដែលមានចរាចរណ៍ច្រើន។ ការប៉ះពាល់រវាងមនុស្សនិងមនុស្សសម្រាប់ការដឹកជញ្ជូនទំនិញ ត្រូវបានលុបបំបាត់នៅគ្រប់ពេលដែលអាចធ្វើបាន។

## ការពិចារណាលើទីកន្លែង

❑ បន្ទប់ទឹកដែលពីមុនធ្លាប់បើកទ្វារដល់សាធារណជន ត្រូវបន្តបើកទ្វារដល់សាធារណជនដដែល។

❑ បុគ្គលិកម្នាក់ក្នុងមួយវេនត្រូវបានចាត់តាំងឲ្យត្រួតពិនិត្យ និងអនុវត្តដំណើរការធ្វើអនាម័យ និងសម្លាប់មេរោគបន្ថែមតាមការចាំបាច់។

❑ បន្ទប់ទឹកត្រូវមានការត្រួតពិនិត្យជាប្រចាំដែលបានសម្អាត និងសម្លាប់មេរោគយ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ ឬញឹកញាប់តាមដែលបាន ដោយកំណត់វាគឺការងារដ៏ចាំបាច់ដោយប្រើថ្នាំសម្លាប់មេរោគEPA។

❑ គម្រោងសម្អាត និងការសម្លាប់មេរោគសម្រាប់ផ្ទៃដែលមានការប៉ះពាល់ច្រើន និងប្រើប្រាស់រួមត្រូវបានអភិវឌ្ឍ និងអនុវត្ត។

- ទីកន្លែងទូទៅ និងវត្ថុដែលបានប៉ះញឹកញាប់ដែលទាក់ទងនឹងការទៅយកទំនិញរបស់អតិថិជន និងកន្លែងបង់ប្រាក់ (ឧ. តុ ដៃទ្វារ ម៉ាស៊ីនអានកាតគណនាទាន) ត្រូវបានសម្លាប់មេរោគមួយម៉ោងម្តងឬច្រើនម៉ោងធ្វើការដោយប្រើសារធាតុសម្លាប់មេរោគដែលបានអនុញ្ញាតដោយ EPA។
- បន្ថែមការសម្អាត និងសម្លាប់មេរោគនៅតាមទីតាំងផ្ទៃដែលមានចរាចរណ៍ច្រើន ឬផ្ទៃដែលត្រូវបានប៉ះពាល់ដោយបុគ្គលដែលមិនបានពាក់ម៉ាស់។

❑ ទីកន្លែងត្រូវបានសម្អាត និងធ្វើអនាម័យ/សម្លាប់មេរោគតាមការសមស្រប (ដោយប្រើផលិតផលដែលបានអនុម័តឲ្យប្រើប្រឆាំងនឹងជំងឺ COVID-19) នៅពេលយប់។ កំណត់ត្រាមួយត្រូវបានរក្សាទុកដើម្បីត្រួតពិនិត្យលើការបំពេញនៅគ្រប់ពេលដែលអាចធ្វើបាន។

❑ កាសសំឡេង និងឧបករណ៍ផ្សេងទៀតមិនត្រូវបានចែករំលែកជាមួយបុគ្គលិកឡើយ លុះត្រាឧបករណ៍នោះត្រូវបានសម្លាប់មេរោគបានសមស្របបន្ទាប់ពីប្រើប្រាស់ម្តងៗ។ ប្រឹក្សាជាមួយអ្នកផលិតឧបករណ៍ដើម្បីសម្រេចពីជំហានសម្លាប់មេរោគដែលសមស្រប។

❑ អ្នកលាងចាន ត្រូវបានផ្តល់ឲ្យជាមួយនឹងឧបករណ៍ដើម្បីការពារភ្នែក ច្រមុះ និងមាត់ពីការកខ្វក់ដោយសារការខ្ទាត ដោយប្រើប្រាស់ម៉ាស់ វ៉ែនតាការពារ និង/ឬសន្ទះបាំងមុខ។ អ្នកលាងចានបានទទួលអាវការពារក្រៅ និងចាំបាច់ត្រូវផ្លាស់ប្តូរឲ្យបានញឹកញាប់។ ឧបករណ៍ការពារដែលអាចប្រើប្រាស់ឡើងវិញដូចជាសន្ទះបាំងមុខ និងវ៉ែនតាត្រូវសម្លាប់មេរោគឲ្យបានល្អបន្ទាប់ពីប្រើប្រាស់ម្តងៗ។

❑ ទឹកអនាម័យលាងដៃ និងធុងសម្រាមគឺមានសម្រាប់សាធារណជននៅ ឬជិតច្រកចូលទីកន្លែងសេវាភេសជ្ជៈខាងក្រៅអគារ។

## ទីកន្លែងអតិថិជន/ទីកន្លែងសេវាកម្ម

❑ អតិថិជនត្រូវបានណែនាំថាពួកគេត្រូវតែពាក់ម៉ាស់គ្រប់ពេលដែលពួកគេមិនផឹក។ នេះរាប់បញ្ចូលទាំងពេលចូលមកកាន់ទីកន្លែងអង្គុយខាងក្រៅអគារ ពេលដើរនៅកន្លែងណាមួយក្នុងទីកន្លែងអង្គុយខាងក្រៅអគារ និងនៅពេលប្រើប្រាស់បន្ទប់ទឹកខាងក្រៅអគារ។ នេះអនុវត្តទៅលើមនុស្សធំទាំងអស់ និងកុមារដែលមានអាយុ ពីរឆ្នាំឡើងទៅ។ បុគ្គលដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនថាពួកគេមិនគួរពាក់ម៉ាស់ ត្រូវតែពាក់សន្ទះបាំងមុខដែលមានក្រណាត់គ្របនៅគែមខាងក្រោម ដើម្បីអនុលោមតាមបទបញ្ជារបស់រដ្ឋ ដរាបណាលក្ខខណ្ឌសុខភាពរបស់ពួកគេអនុញ្ញាត។ យកល្អគួរប្រើក្រណាត់គ្របដែលមានទម្រង់រឹងតឹងនៅខាងក្រោមចង្កា។ មិនត្រូវប្រើម៉ាស់ដែលមានវ៉ាល់តែមួយផ្លូវឡើយ។ ដើម្បីគាំទ្រសុវត្ថិភាពរបស់បុគ្គលិកអ្នក និងភ្ញៀវផ្សេងទៀត គេគួរផ្តល់ម៉ាស់ដល់ភ្ញៀវដែលមកដល់ដោយមិនមានវា។

- អតិថិជនអាចដោះម៉ាស់ ខណៈពេលអង្គុយនៅនឹងតុ និងពេលកំពុងផឹកបាន។
- អតិថិជនត្រូវតែអង្គុយដើម្បីទទួលទានភេសជ្ជៈផ្សេងៗ។ អតិថិជនមិនអាចដើរចុះឡើង ឬឈរខណៈពេលកំពុងផឹកបានឡើយ។
- អតិថិជនដែលបដិសេធមិនពាក់ម៉ាស់ អាចត្រូវបានបដិសេធមិនផ្តល់សេវាកម្ម និងស្នើសុំឲ្យចាកចេញ។

❑ ការណែនាំអតិថិជន។ អាជីវកម្មត្រូវតែដាក់ស្លាកសញ្ញា ឬកាត (មិនតូចជាង 3 x 5 អ៊ីញ) នៅនឹងតុជាមួយនឹងការណែនាំដូចខាងក្រោម ឬមានអត្ថន័យស្រដៀងគ្នា បន្ទាប់ពីធ្វើអនាម័យតុនីមួយៗបន្ទាប់ពីក្រុមអតិថិជនប្រើប្រាស់រួច៖

"សូមជួយឲ្យយើងបន្តបើកអាជីវកម្មរបស់យើង ការពារបុគ្គលិករបស់យើង និងការពារអតិថិជនដូចគ្នាដោយអនុវត្តតាមគោលការណ៍ណែនាំសាមញ្ញៗរបស់យើង៖

ប្រវត្តិ - មិនមានប្រសិទ្ធភាពទៀតទេ

- បន្តពាក់ម៉ាស់រហូតដល់ភេសជ្ជៈរបស់អ្នកត្រូវបានបម្រើជូន និងបន្ទាប់ពីទទួលទានរួច។
- ចូរពាក់ម៉ាស់គ្រប់ពេលដែលអ្នកបម្រើមកជិតតុរបស់អ្នក។
- ចូរពាក់ម៉ាស់គ្រប់ពេលដែលអ្នកចាកចេញពីតុរបស់អ្នក។
- ចូរលាងដៃ ឬធ្វើអនាម័យដៃរបស់អ្នក។

សូមអរគុណសម្រាប់ការជួយការពារសុខភាពបុគ្គលិករបស់យើង និងអតិថិជនដូចគ្នារបស់អ្នក!" ឧទាហរណ៍នៃក្រាហ្វិកសុវត្ថិភាពតុសម្រាប់ជំងឺ COVID-19 (COVID-19 Table Top Safety Graphic) គឺមានសម្រាប់ទាញយកនៅ៖http://publichealth.lacounty. gov/media/Coronavirus/docs/food/TableTop.pdf។ ជម្រើសផ្សេងទៀត ដូចជាស្លាកសញ្ញា ផ្ទាំងឌីជីថលជាដើម អាចត្រូវបានប្រើនៅក្នុងកន្លែងសេវាភេសជ្ជៈដើម្បីជម្រាបជូនព័ត៌មាន និងរំលឹកដល់អតិថិជនអំពីការណែនាំទាំងនេះ នៅពេលដែលពួកគេអង្គុយ និងនៅក្នុងពេលវេលាទាំងមូលដែលពួកគេស្ថិតនៅអាជីវកម្ម។

- ❑ កម្រិតសំឡេងតន្ត្រី ឬទូរទស្សន៍ត្រូវបានលៃតម្រូវដើម្បីធ្វើឲ្យប្រាកដថាបុគ្គលិកទទួលភ្ញៀវ អាចស្តាប់ឮការបញ្ជាទិញរបស់អតិថិជន ដោយមិនបាច់ខិតចូលជិតអតិថិជន។
- ❑ ការពិនិត្យរោគសញ្ញាត្រូវបានធ្វើឡើងមុនពេលអតិថិជនអាចចូលក្នុងទីកន្លែង។ ការពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យពាក់ព័ន្ធនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងគ្រុនក្តៅឬគ្រុនរងា និងថាតើបុគ្គលនោះកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែក ឬឲ្យនៅដាច់ពីគេនាពេលបច្ចុប្បន្នឬអត់។ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានដោយផ្ទាល់ ឬតាមរយៈវិធីផ្សេងដូចជាប្រព័ន្ធចុះឈ្មោះតាមអនឡាញ ឬតាមរយៈស្លាកសញ្ញាដែលបានបិទនៅច្រកចូលទីកន្លែងដោយថ្លែងថាភ្ញៀវដែលមានរោគសញ្ញាទាំងនេះមិនគួរចូលក្នុងទីកន្លែងឡើយ។
    - ការពិនិត្យឃើញអវិជ្ជមាន (គ្មានបញ្ហា)។ បើសិនជាបុគ្គលមិនមានរោគសញ្ញា និងមិនបានប៉ះពាល់ជាមួយករណីដែលគេដឹងថាជាករណីជំងឺ COVID-19 ក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ពួកគេអាចចូលសម្រាប់ថ្ងៃនោះបាន។
    - ការពិនិត្យឃើញវិជ្ជមាន (មានបញ្ហា)៖
        - បើសិនជាបុគ្គលមានការប៉ះពាល់ជាមួយករណីដែលគេដឹងថាមានជំងឺ COVID-19 ក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ឬបច្ចុប្បន្នកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ពីគេ ពួកគេមិនអាចចូលបានឡើយ និងត្រូវតែត្រឡប់ទៅផ្ទះវិញភ្លាមៗដើម្បីនៅដាច់ពីគេ។ ផ្តល់ឲ្យពួកគេនូវការណែនាំអំពីការដាក់ឲ្យនៅដាច់ពីគេដែលមាននៅ ph.lacounty.gov/covidquarantine។
        - បើសិនជាបុគ្គលកំពុងចេញរោគសញ្ញាណាមួយនៃរោគសញ្ញាដែលបានកត់សម្គាល់ខាងលើ ឬកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែកនាពេលបច្ចុប្បន្ន ពួកគេមិនអាចចូលបានទេ និងត្រូវតែបញ្ជូនទៅផ្ទះភ្លាមៗដើម្បីនៅដាច់ដោយឡែកនៅផ្ទះ។ ផ្តល់ឲ្យពួកគេនូវការណែនាំអំពីការដាក់ឲ្យនៅដាច់ដោយឡែកដែលមាននៅ ph.lacounty.gov/covidisolation។
- ❑ អ្នកបម្រើ អ្នកសម្អាតតុ និងបុគ្គលិកផ្សេងទៀតដែលកំពុងផ្លាស់ទីវត្ថុដែលបានប្រើដោយអតិថិជន (ពែង ចាន កន្សែងកខ្វក់ ។ល។) ឬចាត់ចែងថង់សម្រាមគឺត្រូវលាងដៃបន្ទាប់បំពេញការងាររួចរាល់។
- ❑ ម៉ឺនុយដែលអាចប្រើប្រាស់ឡើងវិញ ត្រូវបានសម្អាត និងសម្លាប់មេរោគបន្ទាប់ពីអតិថិជនប្រើប្រាស់ម្តងៗ។ ជម្រើសផ្សេងដូចជាផ្ទាំងម៉ឺនុយនឹងថ្កល់ ម៉ឺនុយអេឡិចត្រូនិក ឬម៉ឺនុយដែលអាចទាញយកតាមរយៈឧបករណ៍ចល័តគួរត្រូវបានពិចារណា។
- ❑ កន្លែងអង្គុយរបស់អតិថិជនត្រូវបានសម្អាត និងធ្វើអនាម័យបន្ទាប់ពីប្រើប្រាស់ម្តងៗ។ កន្លែងអង្គុយ តុ និងវត្ថុផ្សេងៗទៀតនៅលើតុត្រូវតែសម្រាប់ប្រើតែម្តង ឬត្រូវបានសម្អាត/ធ្វើអនាម័យបន្ទាប់ពីអតិថិជនប្រើប្រាស់ម្តងៗ។ តុនីមួយៗមានក្រណាត់គ្របមួយដែលត្រូវបានផ្លាស់ប្តូរចន្លោះភ្ញៀវ ឬផ្ទៃគ្មានរន្ធរឹងមាំដែលត្រូវបានធ្វើអនាម័យក្នុងចន្លោះភ្ញៀវ។
- ❑ ប្រអប់សម្រាប់យកទៅផ្ទះ (to-go) ត្រូវបានបំពេញដោយអតិថិជន និងមានតាមសំណើ។
- ❑ ការធ្វើប្រតិបត្តិការដោយមិនប្រើសាច់ប្រាក់ ត្រូវបានលើកទឹកចិត្ត។ បើសិនជាសមស្របសម្រាប់ទីកន្លែង អតិថិជនត្រូវបានអនុញ្ញាតឲ្យឆូតកាតឥណទាន/ឥណពន្ធរបស់ខ្លួន ហើយឧបករណ៍អានកាតត្រូវបានធ្វើអនាម័យយ៉ាងពេញលេញ បន្ទាប់ពីភ្ញៀវប្រើម្តងៗ។
- ❑ ក្រណាត់ដែលប្រើប្រាស់នៅតុអតិថិជនដូចជាកម្រាលតុ និងកន្សែងគួរត្រូវបានយកចេញបន្ទាប់ពីការប្រើប្រាស់ ដោយអតិថិជននីមួយៗ។ បុគ្គលិកគួរពាក់ស្រោមដៃនៅពេលចាត់ចែងក្រណាត់ប្រឡាក់។
- ❑ ស្រេចចិត្ត – ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត (ឧ. ការផ្តល់ម៉ោងសម្រាប់តែជនចាស់ជរា ការផ្តល់ការលើកទឹកចិត្តសម្រាប់ការលក់នៅក្រៅម៉ោងរវល់ខ្លាំង)៖

__________________________________________________________________

## D. វិធានការណ៍ដែលទំនាក់ទំនងជាមួយសាធារណជន

- ❑ ច្បាប់ចម្លងនៃពិធីការនេះ ឬវិញ្ញាបនបត្រអនុលោមភាពសុវត្ថិភាព COVID-19 ខោនធី Los Angeles ដែលបានបោះពុម្ពរបស់ទីកន្លែង ត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលសាធារណៈទាំងអស់មកក្នុងអគារ។ សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីបំពេញកម្មវិធីបញ្ជាក់ដោយខ្លួនឯងនូវអនុលោមភាពសុវត្ថិភាពជំងឺ COVID-19 សូមចូលទៅកាន់ http://publichealth.lacounty.gov/eh/covid19cert.htm. ទីកន្លែងត្រូវតែរក្សាទុកច្បាប់ចម្លងរបស់ពិធីការ

នេះនៅនឹងទីកន្លែងអាជីវកម្មសម្រាប់ការពិនិត្យឡើងវិញទៅតាមការស្នើសុំ។

- ❑ ស្លាកសញ្ញាត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលទាំងអស់ដើម្បីរំលឹកដល់អតិថិជនឲ្យរក្សាគម្លាតរាងកាយប្រាំមួយហ្វីត លាងដៃ ឬប្រើទឹកអនាម័យលាងដៃនៅពេលចូលក្នុងភោជនីយដ្ឋាន ឲ្យពាក់ម៉ាស់ពេលមិនបរិភោគ ឬផឹក និងនៅផ្ទះបើសិនជាពួកគេឈឺ ឬមានរោគសញ្ញាដូចគ្នានឹងជំងឺ COVID-19។ មើល គេហទំព័រការណែនាំអំពីជំងឺ COVID-19 របស់ DPH ប្រចាំខោនធី សម្រាប់ធនធានបន្ថែម និងគំរូស្លាកសញ្ញាដែលអាចត្រូវបានប្រើដោយអាជីវកម្ម។
- ❑ ច្រកអនឡាញរបស់អាជីវកម្ម (គេហទំព័រ បណ្តាញសង្គម ។ល។) ផ្តល់ព័ត៌មានច្បាស់លាស់អំពីម៉ោងបើកទីកន្លែង ការតម្រូវឲ្យប្រើម៉ាស់ គោលការណ៍ទាក់ទងនឹងការបញ្ជាទិញជាមុន ការកក់ទុក ការបង់ប្រាក់ជាមុន ការមកយកទំនិញនិង/ឬការដឹកជញ្ជូន និងបញ្ហាដែលពាក់ព័ន្ធផ្សេងៗទៀត។

## E. វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

- ❑ សេវាកម្មដែលចាំបាច់ខ្លាំងសម្រាប់អតិថិជន ត្រូវបានផ្តល់អាទិភាព។
- ❑ ប្រតិបត្តិការ ឬសេវាកម្មដែលអាចត្រូវបានផ្តល់ពីចម្ងាយ ត្រូវបានប្តូរទៅអនឡាញ។
- ❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការទទួលបានទំនិញ និងសេវាកម្មសម្រាប់អតិថិជនដែលមានការ លំបាកក្នុងការផ្លាស់ទី និង/ឬដែលមានហានិភ័យ (risk) ខ្ពស់នៅទីសាធារណៈ។

**វិធានការណ៍បន្ថែមទាំងឡាយដែលខុសពីខាងលើ គួរត្រូវបានរាយនៅលើទំព័រដាច់ដោយឡែក ដែលអាជីវកម្មគួរភ្ជាប់ជាមួយឯកសារនេះ។**

**អ្នកអាចទាក់ទងបុគ្គលខាងក្រោមជាមួយសំណួរផ្សេងៗអំពីពិធីការនេះ៖**

**ឈ្មោះទំនាក់ទំនងអាជីវកម្ម៖** ______________________

**លេខទូរសព្ទ៖** ______________________

**កាលបរិច្ឆេទកែសម្រួលចុងក្រោយ៖** ______________________

ច្បាប់ចម្លងមិនទាន់ប្រើប្រាស់ - បិទទំព័រ

## គំនូសតាងកន្លែងអង្គុយ

គំនូសតាងប្រាំមួយ(6) នេះមានគោលបំណងដើម្បីប្រើជា ឧទាហរណ៍សម្រាប់ការរៀបចំនៅខាងក្នុងផ្ទះនិងខាងក្រៅ។ របាំងមិនអាចត្រូវបានប្រើដើម្បីកាត់បន្ថយចន្លោះរវាងអតិថិជន និងដើម្បីបង្កើនចំនួនកន្លែងអង្គុយបានឡើយ។ ការបែងចែកតុដោយមានគម្លាត 8 ហ្វីតដោយគិតពីគែមតុមួយដល់គែមតុមួយទៀត នឹងត្រូវជាធានាបាននូវការរក្សាគម្លាតរវាងកាយយ៉ាងតិច 6 ហ្វីត រវាងអតិថិជនពីគ្រួសារផ្សេងទៀត។

គំនូសតាង 1




**នៅជាប់គ្នា**
6 ហ្វីតរវាងគែមកៅអីមួយទៅគែមកៅអី មួយទៀត

គំនូសតាង 2




**ការរៀបរៀងកែង**
6 ហ្វីតរវាងកៅអីមួយរបស់អតិថិជនដែលនៅជាប់គែមតុនៃកៅអីមួយទៀត

គំនូសតាង 3




**នៅជាប់គ្នា**
6 ហ្វីតរវាកៅអីនៅខាងក្រោយទៅកៅអីនៅខាងក្រោយមួយទៀត

គំនូសតាង 4




**ការរៀបចំកន្លែងអង្គុយ**
6 ហ្វីតរវាងគែមតុមួយទៅគែមតុមួយទៀត
រក្សាគម្លាតរវាងភ្ញៀវគឺយ៉ាងហោចណាស់ 6ហ្វីត
ដោយដាក់ចំកណ្តាលតុ

គំនូសតាង 5




**ការ[illegible]តជុំគ្នា ដោយមានប្រើរបាំង**
6ហ្វីតពីគ្នានៃសមាជិកជិតបំផុតនៅក្នុងពិធីចំកណ្តាលតុ

គំនូសតាង6




**ស្តង់**
ស្តង់ដែលដាក់ថេរអាចអង្គុយបាន ដោយអនុញ្ញាតរក្សាគម្លាតជាអប្បបរមានៃ 6 ហ្វីតរវាងអតិថិជននិងអតិថិជន។